ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.....១៧៧០៧.....អពដ

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ទុលា ឆ្នាំ២០១៣

## សេចក្តីណែនាំ
## អំពីការកំណត់ពន្ធចំពោះ
## ប្រាក់ខ្ចីគ្មានការប្រាក់ ឬការប្រាក់ទាបជាង ឬខ្ពស់ជាងកម្រិតការប្រាក់ទីផ្សារ

អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា១១ និងមាត្រា១២ នៃច្បាប់ស្តីពីសារពើពន្ធ ផ្នែកទី៥.៩ និងផ្នែកទី៨.១ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញលេខ១០៥៩ ប្រក.សហវ.ពដ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ និងយោងតាមការសម្រេចរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២០ខែមករា ឆ្នាំ២០១២ លើលិខិតរបស់អគ្គនាយកដ្ឋានពន្ធដារ លេខ១៣០៤ អពដ ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១១ ដើម្បីឱ្យមានសង្គតិភាពក្នុងការកំណត់ពន្ធលើប្រាក់ខ្ចី ដែលសហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសខ្ចីពីធនាគារ ឬស្ថាប័នសញ្ញ័យធន ឬខ្ចីពីសហគ្រាសដទៃដោយគ្មានការប្រាក់ ឬការប្រាក់ទាបជាងឬខ្ពស់ជាង កម្រិតការប្រាក់ទីផ្សារ អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការណែនាំដល់គ្រប់អង្គភាពពន្ធដារ ដូចតទៅ ÷

១- ចំពោះសហគ្រាសដែលបានកត់ត្រាក្នុងតារាងតុល្យការនូវប្រាក់ខ្ចី (Loan) ដែលបានខ្ចីពីធនាគារឬស្ថាប័នសញ្ញ័យធន ឬខ្ចីពីសហគ្រាសដទៃ ប៉ុន្តែគ្មានការកត់ត្រាចំណាយការប្រាក់ អង្គភាពពន្ធដារត្រូវអនុវត្តដូចខាងក្រោម ÷

- ក- មិនត្រូវអនុវត្តការបង្កើត“ចំណាយការប្រាក់ដោយសន្មត (Deemed Interest Expense)” ដើម្បីគោលដៅនៃការកំណត់ពន្ធកាត់ទុកលើសហគ្រាសទេ ស្របតាមផ្នែកទី៨.១.២នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញដែលបានចែងថា “សម្រាប់គោលដៅនៃពន្ធកាត់ទុក ចំណាយណាមួយដែលជាកម្មវត្ថុនៃពន្ធកាត់ទុកដែលបានកត់ត្រាជាចំណាយក្នុងបញ្ជីគណនេយ្យ ត្រូវចាត់ទុកថាបានទូទាត់”។ ដូច្នេះបើសហគ្រាសមិនបានកត់ត្រាចំណាយណាមួយក្នុងបញ្ជីគណនេយ្យ ចំណាយនោះត្រូវបានចាត់ទុកថាមិនបានទូទាត់ និងមិនមែនជាកម្មវត្ថុនៃពន្ធកាត់ទុកទេ។
- ខ- មិនត្រូវអនុវត្តការបង្កើត “ចំណូលពីឧបត្ថម្ភកធនដោយសន្មត (Deemed Subsidy)” ដើម្បីគោលដៅនៃការកំណត់ប្រាក់ចំណូលជាប់ពន្ធលើប្រាក់ចំណេញចំពោះសហគ្រាសឡើយ។

២- ចំពោះសហគ្រាសដែលបានកត់ត្រាក្នុងតារាងតុល្យការនូវប្រាក់ខ្ចី (Loan) ដែលបានខ្ចីពីធនាគារឬស្ថាប័នសញ្ញ័យធន ឬខ្ចីពីសហគ្រាសដទៃ ដោយមានការប្រាក់ទាបជាងកម្រិតការប្រាក់ទីផ្សារ អង្គភាពពន្ធដារមិនត្រូវបង្កើតចំណាយការប្រាក់ដោយសន្មត ដើម្បីកំណត់ពន្ធកាត់ទុក ឬបង្កើតចំណូលពីការឧបត្ថម្ភកធនដោយសន្មតដើម្បីកំណត់ប្រាក់ចំណូលជាប់ពន្ធលើចំណែកនៃការប្រាក់ដែលទាបជាងកម្រិតការប្រាក់ទីផ្សារឡើយ។

Collection by VCAT Professional Consultant

៣- ចំពោះសហគ្រាសដែលបានកត់ត្រាក្នុងតារាងតុល្យការនូវប្រាក់ខ្ចី (Loan) ដែលបានខ្ចីពីធនាគារឬស្ថាប័នសញ្ជ័យធន ឬខ្ចីពីសហគ្រាសដទៃ ហើយបានកត់ត្រាចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធអង្គភាពពន្ធដារត្រូវ ÷

ក- ពិនិត្យអត្រាការប្រាក់ថាតើសមស្របនឹងអត្រាការប្រាក់ទីផ្សារឬទេ។ ក្នុងករណីដែលចំណាយការប្រាក់បានកត់ត្រាខ្ពស់ជាងកម្រិតអត្រាការប្រាក់ទីផ្សារ ត្រូវធ្វើការកែតម្រូវក្រោបញ្ជីគណនេយ្យនូវចំនួនទឹកប្រាក់ឱ្យសមស្របទៅនឹងអត្រាការប្រាក់ទីផ្សារ។ ចំណែកការប្រាក់ដែលលើសពីការប្រាក់តាមកម្រិតអត្រាការប្រាក់ទីផ្សារ ត្រូវបានកាត់ចេញពីខ្ទង់ចំណាយការប្រាក់។ សម្រាប់គោលដៅនៃពន្ធលើប្រាក់ចំណេញកម្រិតអត្រាការប្រាក់ទីផ្សារគឺ ÷

- អត្រាការប្រាក់មធ្យមប្រចាំឆ្នាំរបស់ Singapore Interbank Offered Rate (SIBOR) បូកនឹង៦ភាគរយ ក្នុងករណីប្រាក់ខ្ចីពីបរទេស ។
- អត្រាការប្រាក់មធ្យមប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា ក្នុងករណីប្រាក់ខ្ចីក្នុងស្រុក។

ខ- ក្រោយការកែតម្រូវទឹកប្រាក់ចំណាយការប្រាក់ដូចក្នុងចំណុច “ក” ខាងលើរួចហើយត្រូវអនុវត្តកំហិតនៃការកាត់កងចំណាយការប្រាក់ក្នុងឆ្នាំជាប់ពន្ធតាមមាត្រា១២ នៃច្បាប់ស្តីពីសារពើពន្ធ និងផ្នែកទី៥.៩ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ ដោយកំណត់ចំណាយការប្រាក់ដែលអាចកាត់កងបានក្នុងឆ្នាំជាប់ពន្ធមិនឱ្យលើសពីផលបូកនៃចំណូលការប្រាក់របស់សហគ្រាស និង៥០ភាគរយនៃប្រាក់ចំណេញសុទ្ធក្រៅពីការប្រាក់របស់សហគ្រាសនៅក្នុងឆ្នាំជាប់ពន្ធ។

៤- រាល់ប្រាក់ខ្ចីដូចបានបរិយាយក្នុងចំណុចទី១ ទី២ និងទី៣ខាងលើ សហគ្រាសត្រូវមានឯកសារគាំទ្រដូចខាងក្រោម ÷

ក- កិច្ចសន្យាឬកិច្ចព្រមព្រៀងខ្ចីប្រាក់ដែលមានការបញ្ជាក់ពីមេធាវីនៃភាគីទាំងសងខាង

ខ- ឯកសារផ្ទេរប្រាក់ទាក់ទិននឹងកិច្ចសន្យាឬកិច្ចព្រមព្រៀងខ្ចីប្រាក់

គ- កំណត់ត្រាត្រឹមត្រូវនិងច្បាស់លាស់ក្នុងបញ្ជីគណនេយ្យ។

ក្នុងករណីដែលសហគ្រាសគ្មានឯកសារគាំទ្រតាមការតម្រូវក្នុងចំណុច “ក” “ខ” និង “គ” ខាងលើនេះ ប្រាក់ខ្ចីត្រូវបានចាត់ទុកថាជាប្រាក់ខ្ចីគ្មានភស្តុតាងបញ្ជាក់ ដែលនាំឱ្យកើនឡើងនូវទ្រព្យសកម្មពិត និងត្រូវគិតបញ្ចូលជាប្រាក់ចំណេញជាប់ពន្ធស្របតាមខ្លឹមសារនៃផ្នែកទី២.២.៣.ច នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ។

គ្រប់អង្គភាពពន្ធដារត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

**ចម្លងជូន** :
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  “ដើម្បីជូនជ្រាប”
- គ្រប់អង្គភាពពន្ធដារ
  “ដើម្បីអនុវត្ត”
- ឯកសារ-កាលប្បវត្តិ

Collection by VCAT Professional Consultant